00271320

E8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 19 / 01 / 2009
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Auy

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ
Case File/ Dossier N° 001/18-07-2007-ECCC/TC

| | | |
|---|---|---|
| ចំពោះមុខ | ចៅក្រម និល ណុន ប្រធាន | |
| | ចៅក្រម Silvia CARTWRIGHT | |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រម ធូ មណី | |
| កាលបរិច្ឆេទ | ១៩ ខែ មករា ឆ្នាំ ២០០៩ | |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ | |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Auy

# សេចក្តីសម្រេចស្តីពីការកំណត់កាលបរិច្ឆេទសវនាការបឋម

**សហព្រះរាជអាជ្ញា**

ជា លាង

Robert PETIT

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី

ហុង គីមសួន

យុង ផានិត

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ

François ROUX

អង្គជំនុំជម្រះសាលាដំបូង * TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE * E C C C T C

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៨-៩១៤ ទូរសារ: (៨៥៥)-២៣-២១៨-៩៤១ គេហទំព័រ: www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh. Mail Po Box 71, Tel:+855(0)23 218914 Fax:023 218941 Web: www.eccc.gov.kh

00271321

E8



Pierre Olivier SUR

យើងចៅក្រម **និល ណុន** ជាប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")

**អនុលោមតាម** បទប្បញ្ញត្តិនៃវិធាន ៧៩ ៨០ និង៨០ស្ទួន នៃវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា( "វិធាន")។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ ("សេចក្តីសម្រេច")

**បានឃើញ** សេចក្តីសម្រេចខាងលើចោទប្រកាន់លើឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ភេទប្រុស ជាតិខ្មែរ កើតនៅថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ដោយបញ្ជូនឈ្មោះនេះមកជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពីបទ៖

> តាមរយៈការប្រព្រឹត្តរបស់គាត់ និងការមិនបានទប់ស្កាត់មិនឱ្យមានការប្រព្រឹត្តនៅក្នុងភ្នំពេញ និងនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ មករា ឆ្នាំ ១៩៧៩ ក្នុងឋានៈជាលេខារង និងលេខាមន្ទីរ ស ២១ ដែលបានរៀបចំផែនការ ញុះញង់ បញ្ជា និងបានប្រព្រឹត្ត ឬជួយនិងបង្កលក្ខណៈងាយស្រួល ឬជាអ្នកទទួលខុសត្រូវជាន់ខ្ពស់នូវបទល្មើសឧក្រិដ្ឋកម្មដូចខាងក្រោម៖

**១. បទល្មើសប្រឆាំងមនុស្សជាតិ**

- ការធ្វើមនុស្សឃាត
- ការសំលាប់រង្គាល
- ការធ្វើឱ្យទៅជាទាសករ
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភលើផ្លូវភេទ

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

- ការធ្វើទុកបុកម្នេញ ដោយមូលហេតុនយោបាយ
- និងអំពើអមនុស្សធម៌ផ្សេងៗទៀត

បទល្មើសដែលមានចែង និងត្រូវផ្ដន្ទាទោសតាមមាត្រា ៥ ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

**២. អំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩**

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រូបរាងកាយ ឬសុខភាព
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់
- ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

បទល្មើសដែលមានចែង និងត្រូវផ្ដន្ទាទោសតាមមាត្រា ៦ ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃ កម្ពុជាប្រជាធិបតេយ្យ ។

**៣. ការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦**

- បទមនុស្សឃាតគិតទុកជាមុន (មាត្រា ៥០១ និងមាត្រា ៥០៦)
- បទទារុណកម្ម (មាត្រា ៥០០)

បទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា៣(ថ្មី) មាត្រា២៩(ថ្មី) មាត្រា៣៩(ថ្មី)នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

**បានឃើញផងដែរ** នូវមតិរបស់ភាគីដែលបានលើកឡើងក្នុងអង្គុំពេលកិច្ចប្រជុំរៀបចំសវនាការ ដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី១៥ និង ១៦ ខែ មករា ឆ្នាំ ២០០៨ ។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

**ដោយយល់ឃើញថា** តាមបទប្បញ្ញត្តិមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូង ត្រូវធានាថាសវនាការប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី ។

**ហេតុដូច្នេះ**

១. **សម្រេច** កំណត់កាលបរិច្ឆេទសវនាការបឋមលើរឿងក្តីលេខ ០០១/១៨កក្កដា២០០៧-អវតក/អជសង ដែលមានជនជាប់ចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងថ្ងៃបន្តបន្ទាប់រហូតដល់ចប់សវនាការបឋម នៅវេលាម៉ោង ៩.០០ នាទីព្រឹក នៅសាលសវនាការរបស់ អ.វ.ត.ក ។

២. **ដោយរំលឹកឡើងវិញផងដែរថា** តាមបទប្បញ្ញត្តិនៃវិធាន ២៣ អនុវិធាន ៤ នៃវិធានផ្ទៃក្នុង ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ទៅអង្គភាពជនរងគ្រោះយ៉ាងតិចរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការមុនកាលបរិច្ឆេទសវនាការបឋម មានន័យថាមិនឱ្យលើសពីថ្ងៃ ច័ន្ទ ទី ២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ម៉ោង ១៦.០០ នាទី ។

៣. **ដោយរំលឹកឡើងវិញផងដែរថា** តាមបទប្បញ្ញត្តិនៃវិធាន ៨០ អនុវិធាន ៤ នៃវិធានផ្ទៃក្នុង ការជូនដំណឹងអំពីដីកានេះត្រូវចាត់ទុកជាការបង្គាប់ឱ្យចូលខ្លួន ដែលមានសុពលភាព ។

៤. **សម្រេចថែមទៀតថា** សេចក្តីសម្រេចនេះនឹងត្រូវជូនដំណឹងដល់គ្រប់ភាគីទាំងអស់ និងអង្គភាពជនរងគ្រោះ ដោយអនុលោមតាមវិធាន ៤៧ នៃវិធានផ្ទៃក្នុង និងត្រូវផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C E T C

និល ណុន